# ទិវាមិនប្រើប្រាស់ថ្នាំពុល

នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៨ បណ្ដាញសកម្មភាពកាត់បន្ថយថ្នាំពុលកម្ពុជាដែលមានអង្គការសេដាកជាសមាជិក បានរៀបចំធ្វើពិធីមួយស្ដីពីទិវាមិនប្រើថ្នាំពុលនៅទីរួមខេត្តសៀមរាប។ អ្នកចូលរួមប្រមាណ ៦០០ នាក់ដែលរួមមានកសិករ សិស្ស-និស្សិត មន្ត្រីរាជការ អជ្ញាធរមូលដ្ឋាន តំណាងអង្គការក្រៅរដ្ឋាភិបាល ពាណិជ្ជករ និងអ្នកសារព័ត៌មានបានចូលរួមនៅក្នុងពិធីនេះ។ ពិធីនេះចាប់ផ្ដើមដោយការដើរក្បួនរយៈពេលពីរម៉ោង ឆ្លងកាត់ទីរួមខេត្តសៀមរាប រួចវិលត្រឡប់ប្រារព្ធពិធីនៅក្នុងបរិវេណមន្ទីរកិច្ចការនារីខេត្តសៀមរាប ក្រោមអធិបតីភាពឯកឧត្តម **ប៊ុន ថាឫទ្ធិ** អភិបាលរងខេត្តសៀមរាប។

គោលបំណងសំខាន់នៃទិវានេះរួមមានៈ



- បង្កើនការយល់ដឹងជាសាធារណៈអំពីទិវាគ្មានប្រើប្រាស់ថ្នាំពុលគីមី
- ទាក់ទាញការចាប់អារម្មណ៍ចំពោះផលប៉ះពាល់ពីការប្រើប្រាស់ថ្នាំពុលគីមី ដែលកំពុងបន្តការគំរាមកំហែងដល់អាយុជីវិតមនុស្ស និងបរិស្ថាន។
- ជំរុញលើកទឹកចិត្តកសិករ ដើម្បីអនុវត្តគោលការណ៍ និងបច្ចេកទេសកសិកម្មតាមគោលការណ៍ធម្មជាតិ។

គួរបញ្ជាក់ថា បើតាមរបាយការណ៍ អង្គការសុខភាពពិភពលោកបានបង្ហាញថា ប្រជាជនប្រមាណ ២០០ ០០០ នាក់បានរងគ្រោះដោយសារការពុលថ្នាំពុលនេះជារៀងរាល់ឆ្នាំ បើគិតជាថ្ងៃវិញ ឃើញថាមាន ៥៤៧ នាក់ ត្រូវបានស្លាប់ដោយសារថ្នាំពុលជារៀងរាល់ថ្ងៃ។